ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិសម្រាប់កម្មវិធី
ជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ
(MAFF-NIO for Rice-SDP)

ADB
Asian Development Bank

# សៀវភៅណែនាំ
# ស្តីពី
# ផលិតកម្មគ្រាប់ពូជស្រូវ
# (Rice Seed Production Manual)





## កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ
**Climate-Resilient Rice Commercialization Sector Development Program (Rice-SDP)**

កក្កដា-២០១៨ / July-2018

## អ្នករៀបរៀង

១. លោកបណ្ឌិត **ខិន នាយ** ប្រធាននាយកដ្ឋានដំណាំស្រូវ និងជាប្រធានសម្របសម្រួលកម្មវិធីគម្រោងនៃអង្គភាព **MAFF-NIO for Rice-SDP**

២. លោក **ឈិត ស៊ីថា** ទីប្រឹក្សាថ្នាក់ជាតិផ្នែកវិញ្ញាបនបត្រគ្រាប់ពូជស្រូវនៃអង្គភាព **MAFF-NIO for Rice-SDP**

៣. លោក **ពេជ ផល្លី** ប្រធានការិយាល័យស្រាវជ្រាវ និងបណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ និងជាមន្ត្រីទទួលបន្ទុកបច្ចេកទេសដំណាំស្រូវនៃអង្គភាព **MAFF-NIO for Rice-SDP**។

## អ្នកផ្តល់យោបល់កែសម្រួល

១. ឯកឧត្តម **គិត សេង** អនុរដ្ឋលេខាធិការ និងជានាយកគម្រោងថ្នាក់ជាតិសម្រាប់កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **(MAFF-NIO for Rice-SDP)**

២. លោកបណ្ឌិត **Rajendra Kumar Trivedi** ទីប្រឹក្សាអន្តរជាតិផ្នែកវិញ្ញាបនបត្រគ្រាប់ពូជស្រូវ នៃអង្គភាព **MAFF-NIO for Rice-SDP**

៣. លោក **អឿន សុផាត** ទីប្រឹក្សាថ្នាក់ជាតិផ្នែកកសិកម្ម និងក្រោយប្រមូលផល (ប្រធានក្រុមទីប្រឹក្សា) នៃអង្គភាព **MAFF-NIO for Rice-SDP**

៤. លោក **ហ៊ុយ គាវុធ** ទីប្រឹក្សាថ្នាក់ជាតិផ្នែកកំណត់តំបន់ប្រើប្រាស់ដីកសិកម្ម នៃអង្គភាព **MAFF-NIO for Rice-SDP**

៥. លោក **គង់ គា** អនុប្រធាននាយកដ្ឋានដំណាំស្រូវ នៃអគ្គនាយកដ្ឋានកសិកម្ម

៦. លោក **សាក់ ឡឿន** ទីប្រឹក្សាថ្នាក់ជាតិ នៃគម្រោង **RSPP-JICA**

៧. លោក **អ៊ុច ចាន់ថុល** ប្រធានភាពជាដៃគូ និងទំនាក់ទំនង នៃវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ ការិយាល័យប្រចាំនៅកម្ពុជា **(IRRI CAMBODIA)**

៨. លោកស្រី **អ៊ុន សុភា** មន្ត្រីទទួលបន្ទុកគ្រប់គ្រងកិច្ចសន្យា នៃអង្គភាព **MAFF-NIO for Rice-SDP**

៩. លោក លោកស្រី ជាមន្ត្រី នៃអង្គភាព **MAFF-NIO for Rice-SDP**។

ម.ព.ឯ.ក AIDOC
Code: 260-005
Date:
Donated by:

# អារម្ភកថា

ស្រូវគឺជាស្បៀងដ៏សំខាន់សម្រាប់មនុស្សនៅលើពិភពលោក  ជាពិសេសនៅក្នុងទ្វីបអាស៊ីដែលតម្រូវការអង្ករលើពិភពលោក នឹងកើនឡើងដល់៤៩៦លានតោនក្នុងឆ្នាំ២០២០ និង៥៥៣លានតោនក្នុងឆ្នាំ២០៣៥។ ដោយឡែក នៅព្រះរាជាណាចក្រកម្ពុជា មានប្រជាជនភាគច្រើនបំផុតដែលទទួលទានបាយ ហើយរាជរដ្ឋាភិបាលបានកំណត់ថាស្រូវ-អង្ករគឺជាមាសសសម្រាប់ផ្គត់ផ្គង់ជីវភាពប្រជាជនក្នុងស្រុក និងជាកម្មវត្ថុដ៏ចម្បងមួយនៃការធ្វើពាណិជ្ជកម្មក្រៅប្រទេស។

ផលិតកម្មដំណាំស្រូវ និងការកែច្នៃអង្ករនៅកម្ពុជាបច្ចុប្បន្ន ពុំទាន់ឆ្លើយតបពេញលេញទៅនឹងការតម្រូវផ្នែកគុណភាព និងស្តង់ដារទីផ្សារក្នុងស្រុក និងក្រៅស្រុកនៅឡើយ ដោយសារជួបបញ្ហាមួយចំនួនដូចជា កង្វះគ្រាប់ពូជស្រូវមានគុណភាព បច្ចេកទេសផលិតកម្មនៅមានកម្រិត និងសម្ភារ/ឧបករណ៍កែច្នៃទំនើបមានមិនទាន់គ្រប់គ្រាន់ជាដើម។

បច្ចុប្បន្ន មានការផលិតគ្រាប់ពូជស្រូវ និងលក់ចែកចាយលើទីផ្សារក្នុងទ្រង់ទ្រាយតូចដោយមិនទាន់មានប្រព័ន្ធបញ្ជាក់គុណភាពនៅឡើយ។ ការអនុវត្តផលិតកម្មគ្រាប់ពូជស្រូវរបស់ផលិតករប្រព្រឹត្តទៅដោយពុំទាន់មានការយល់ដឹងអំពីលក្ខណៈបច្ចេកទេសឱ្យបានគ្រប់គ្រាន់ និងមិនទាន់មានគុណភាពស្របតាមស្តង់ដារដែលបានកំណត់។ ម្យ៉ាងទៀត ការថែរក្សាទុកដាក់មិនទាន់បានត្រឹមត្រូវ និងការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវមិនបានអនុវត្តតាមគោលការណ៍នៅឡើយ។ ដូច្នេះ កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (Rice-SDP) មានគំនិតផ្តួចផ្តើមរៀបចំឯកសារបច្ចេកទេសស្តីពី ផលិតកម្មគ្រាប់ពូជស្រូវនេះឡើង ដើម្បីឱ្យអ្នកផលិតគ្រាប់ពូជស្រូវទាំងឡាយរួមមាន ស្ថានីយកសិកម្ម ក្រុមកសិករ សហគមន៍កសិកម្ម និងក្រុមហ៊ុនឯកជនដែលមានឯកទេសកម្មផ្នែកផលិតកម្មគ្រាប់ពូជស្រូវ យកទៅប្រើប្រាស់ក្នុងការអភិវឌ្ឍ និងអនុវត្តការងារផលិតកម្មគ្រាប់ពូជស្រូវរបស់ខ្លួន។

អ្នករៀបរៀងមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា សៀវភៅណែនាំស្តីពី ផលិតកម្មគ្រាប់ពូជស្រូវនេះនឹងផ្តល់ចំណេះដឹង ការអនុវត្តល្អៗ គំនិតថ្មីៗ និងគោលការណ៍បច្ចេកទេសជាមូលដ្ឋានសម្រាប់តួអង្គពាក់ព័ន្ធយកទៅអនុវត្តដើម្បីលើកកម្ពស់គុណភាពគ្រាប់ពូជស្រូវឱ្យកាន់តែល្អប្រសើរស្របតាមស្តង់ដារ។ លើសពីនេះទៀត ការប្រើប្រាស់គ្រាប់ពូជស្រូវមានគុណភាពល្អ នឹងអាចជួយបង្កើនទិន្នផលស្រូវ និងគុណភាពអង្ករដែលញ៉ាំងឱ្យអ្នកផលិត និងអ្នកកែច្នៃទទួលបានផលចំណេញកាន់តែប្រសើរ។

ការចងក្រងសៀវភៅនេះបានដកស្រង់ខ្លឹមសារបច្ចេកទេសពីឯកសាររបស់ស្ថាប័នពាក់ព័ន្ធនានា គួបផ្សំជាមួយនឹងបទពិសោធន៍អនុវត្តជាក់ស្តែងកន្លងមក។

យើងខ្ញុំសូមស្វាគមន៍ទទួលយកនូវរាល់យោបល់កែលម្អបន្ថែមទៀតពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធដើម្បីធ្វើឱ្យសៀវភៅនេះកាន់តែមានលក្ខណៈល្អគ្រប់ជ្រុងជ្រោយ។

ថ្ងៃ...........................ខែ..................ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ............ ឆ្នាំ២០១៨

**អង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិសម្រាប់កម្មវិធីជំរុញផលិតកម្មស្រូវ**

**និងការនាំចេញអង្ករ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**(MAFF-NIO for Rice-SDP)**

# មាតិកា


**អក្សរកាត់** ........ v

**១. សាវតារ** ........ 1

**២. វត្ថុបំណងរបស់សៀវភៅ** ........ 2

**៣. ការចាត់ថ្នាក់គ្រាប់ពូជស្រូវ** ........ 3

៣.១. ការចាត់ថ្នាក់គ្រាប់ពូជស្រូវ ........ 3

៣.២. ស្តង់ដារគុណភាពគ្រាប់ពូជស្រូវ ........ 4

**៤. បច្ចេកទេសផលិតកម្មគ្រាប់ពូជស្រូវ** ........ 6

៤.១. ផែនការផលិតកម្មគ្រាប់ពូជស្រូវ ........ 6

៤.២. ប្រភពគ្រាប់ពូជស្រូវ ........ 7

៤.៣. ការជ្រើសរើសទីតាំងស្រែផលិតកម្មគ្រាប់ពូជស្រូវ ........ 7

៤.៤. ការរៀបចំដី ........ 8

៤.៥. ការរៀបចំធ្វើសំណាប ........ 9

៤.៥.១. សំណាបថ្នាលសើម ........ 9

៤.៥.២. ការធ្វើថ្នាលដាប៉ុក ........ 12

៤.៦. ការស្ទូង ........ 12

៤.៧. ការជួសគុម្ព ........ 14

៤.៨. ការកម្ចាត់ពូជលាយ និងស្មៅ ........ 15

៤.៩. ការគ្រប់គ្រងទឹក ........ 17

៤.១០. ការគ្រប់គ្រងជីជាតិដី ........ 17

៤.១១. ការគ្រប់គ្រងសត្វល្អិតចង្រៃ និងជំងឺ ........ 19

៤.១២. ការងារប្រមូលផល ........ 20

៤.១២.១. ការច្រូតកាត់ដោយដៃ ឬម៉ាស៊ីនច្រូតពាក់កណ្តាលស្វ័យប្រវត្តិ (ត្រង់ដី) ........ 21

៤.១២.២. ការច្រូតដោយម៉ាស៊ីនទំនើប ........ 21

៤.១៣. ប្រតិបត្តិការក្រោយការច្រូតកាត់ និងការកែច្នៃគ្រាប់ពូជ (នៅមជ្ឈមណ្ឌលកែច្នៃគ្រាប់ពូជ) ........ 22

៤.១៣.១. ការបោកស្រូវ ........ 22

៤.១៣.២. ការដឹកជញ្ជូន ........ 22

៤.១៣.៣. ការសម្ងួត ........ 23

៤.១៣.៤. ការសម្អាតគ្រាប់ពូជស្រូវ ........ 26

៤.១៣.៥. ការវេចខ្ចប់ ........ 28

៤.១៣.៦. ការស្តុកគ្រាប់ពូជស្រូវ ........ 28

៤.១៣.៧. ការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវ ........ 30

៥. អ្នកផលិតគ្រាប់ពូជស្រូវ ..... 33
៦. កម្មវិធីផលិតគ្រាប់ពូជគ្រឹះ ..... 34
៧. កម្មវិធីផលិតគ្រាប់ពូជចុះបញ្ជី ..... 35
៨. កម្មវិធីផលិតគ្រាប់ពូជវិញ្ញាបនបត្រ ..... 37
៩. សាលារៀនស្រែកសិករសម្រាប់លើកកម្ពស់ផលិតកម្មគ្រាប់ពូជស្រូវ ..... 39
១០. សេចក្តីសន្និដ្ឋាន ..... 39
១១. ឧបសម្ព័ន្ធ និងទម្រង់បែបបទផ្សេងៗ ..... 41
ឧបសម្ព័ន្ធទី១: កិច្ចព្រមព្រៀងសម្រាប់ការផលិតគ្រាប់ពូជស្រូវគ្រឹះ ..... 41
ឧបសម្ព័ន្ធទី២: កិច្ចព្រមព្រៀងសម្រាប់ការផលិតគ្រាប់ពូជស្រូវចុះបញ្ជី ..... 50
ឧបសម្ព័ន្ធទី២.ក: កិច្ចព្រមព្រៀងសម្រាប់ត្រីភាគី ..... 50
ឧបសម្ព័ន្ធទី២.ខ: កិច្ចព្រមព្រៀងសម្រាប់ទ្វេភាគី ..... 62
ឧបសម្ព័ន្ធទី៣: កិច្ចព្រមព្រៀងសម្រាប់ការផលិតគ្រាប់ពូជស្រូវវិញ្ញាបនបត្រ ..... 72
ឧបសម្ព័ន្ធទី៤: កិច្ចព្រមព្រៀងការងារសាលារៀនស្រែកសិករ ..... 86
ឧបសម្ព័ន្ធទី៥: ទម្រង់បែបបទផ្សេងៗ ..... 91
ទម្រង់បែបបទទី១: ស្លាកសម្គាល់គ្រាប់ពូជស្រូវ (ស្លាកសញ្ញាព័ត៌មាន) ..... 91
ទម្រង់បែបបទទី២: ប័ណ្ណសម្គាល់គំនរគ្រាប់ពូជស្រូវ ..... 92
ទម្រង់បែបបទទី៣: ការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវប្រចាំខែ ..... 93
ទម្រង់បែបបទទី៤: កំណត់ត្រាច្រូតកាត់ បោកអោយ និងប្រគល់ ទទួលគ្រាប់ពូជស្រូវនៅទីវាល ..... 94
ទម្រង់បែបបទទី៥: ប័ណ្ណបញ្ជាទិញគ្រាប់ពូជស្រូវ ..... 96
ទម្រង់បែបបទទី៦: អាជ្ញាប័ណ្ណដឹកជញ្ជូន ..... 97
ទម្រង់បែបបទទី៧: សំណើសុំបញ្ចេញ ឬបញ្ចូលទំនិញ ..... 98
ទម្រង់បែបបទទី៨: របាយការណ៍កែច្នៃគ្រាប់ពូជស្រូវ ..... 99
ទម្រង់បែបបទទី៩: របាយការណ៍លទ្ធផលវេចខ្ចប់គ្រាប់ពូជស្រូវ ..... 100
ទម្រង់បែបបទទី១០: របាយការណ៍ស្តុកដោយធ្វើបច្ចុប្បន្នភាព ..... 101
ទម្រង់បែបបទទី១១: ស្តុកគ្រាប់ពូជស្រូវមានក្នុងដៃ ..... 103
ទម្រង់បែបបទទី១២: ២៥ជំហាននៃដំណើរការផលិតគ្រាប់ពូជស្រូវ ..... 104

# អក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CARDI | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| DAP | ជី ដេ អា ប៉េ (ឌីអាម៉ូញ៉ូមផូស្វាត) |
| EFAP | គម្រោងឧបត្ថម្ភស្បៀងបន្ទាន់ |
| KCL | ជី កា សេ អិល (ប៉ូតាស្យូមក្លរួ) |
| MAFF-NIO | អង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| NPK | ជី អិន ប៉េ កា (អាសូត ផូស្វ័រ និងប៉ូតាស្យូម) |
| Rice-SDP | កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ |
| UREA | ជីអ៊ុយរ៉េ |
| គ.ក្រ | គីឡូក្រាម |
| ម | ម៉ែត្រ |
| ហ.ត | ហិកតា |
| ស.ម | សង់ទីម៉ែត្រ |

## ១. សាវតារ

កសិកម្មនៅតែជាវិស័យសំខាន់ជាងគេនៅក្នុងសេដ្ឋកិច្ចកម្ពុជា ដោយរួមចំណែកក្នុងផលិតផលក្នុងស្រុកសរុប (GDP) ចំនួន ៣២% និងផ្តល់ការងារចំនួន ៦០% នៃកម្លាំងពលកម្ម។ ទន្ទឹមនឹងនេះ ប្រជាពលរដ្ឋចំនួន ៨០% ពឹងផ្អែកលើវិស័យកសិកម្មសម្រាប់ជីវភាពរស់នៅរបស់ខ្លួន[1]។ វិស័យកសិកម្មគឺជាកម្លាំងជំរុញសំខាន់មួយដល់កំណើនសេដ្ឋកិច្ចដែលសម្រេចបាននូវកំណើនថេរក្នុងរយៈពេលចាប់ពីឆ្នាំ២០០២ ដល់ ២០១២។ នៅក្នុងវិស័យកសិកម្ម ស្រូវគ្របដណ្តប់ច្រើនជាង ៩០% នៃតំបន់ដាំដុះ ហើយការផលិតស្រូវភាគច្រើនបំផុតគឺសម្រាប់ការប្រើប្រាស់ក្នុងស្រុក។ អនុវិស័យស្រូវមានចំណែកប្រហែល ៥០% នៃទិន្នផលរបស់វិស័យកសិកម្ម។ ដោយសារតួនាទីចម្បងបំផុតនៃវិស័យនេះស្ថិតក្នុងវិស័យសេដ្ឋកិច្ច ការកែប្រែអនុវិស័យស្រូវពីរឿងបន្ទាប់បន្សំឱ្យទៅជាវិស័យតម្រង់ទិសទៅរកអាជីវកម្មគឺជាជម្រើសយុទ្ធសាស្រ្តសម្រាប់ប្រទេសកម្ពុជា ដោយសារតែអនុវិស័យនេះអាចផ្តល់ឱកាសប្រសើរបំផុតដើម្បីលើកកម្ពស់សន្តិសុខស្បៀងថ្នាក់ជាតិ និងពង្រីកការនាំចេញស្រូវ-អង្ករដែលជាលទ្ធផលនៃការកាត់បន្ថយភាពក្រីក្រ។

ដោយបានស្គាល់អំពីឱកាសពិសេសដែលមាននៅក្នុងអនុវិស័យស្រូវសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញនូវបំណងរបស់ខ្លួនតាមរយៈគោលនយោបាយស្រូវដើម្បីកែប្រែប្រទេសកម្ពុជាឱ្យទៅជា "ជង្រុកស្រូវ" ហើយក្លាយជាប្រទេសនាំចេញអង្ករដ៏សំខាន់មួយ។ ក្នុងរយៈកាលប៉ុន្មានឆ្នាំកន្លងមកនេះ ថ្វីត្បិតតែកម្ពុជាសម្រេចបាននូវមូលដ្ឋានសំខាន់ៗខ្លះៗក្នុងវិស័យនាំចេញអង្ករក្តី ប៉ុន្តែនៅតែពុំទាន់អាចសម្រេចបានតាមទិសដៅពេញលេញដែលខ្លួនបានកំណត់នៅក្រោមគោលនយោបាយស្រូវអង្ករនោះឡើយ ពោលគឺការនាំចេញអង្ករឱ្យបានមួយលានតោន។ ដូច្នេះហើយទើបបានជាមានការផ្តោតការយកចិត្តទុកដាក់សារជាថ្មីពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាលើការកែលម្អការផ្គត់ផ្គង់ និងការគ្រប់គ្រងទឹកហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារសម្ងួត និងឃ្លាំង ការផ្សារភ្ជាប់ទំនាក់ទំនងទីផ្សារ ហើយសំខាន់បំផុតនោះគឺការធ្វើឱ្យមានគ្រាប់ពូជគុណភាពខ្ពស់សម្រាប់ផលិតកម្មស្រូវ។

ដោយពិចារណាលើចំណុចនេះ កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (Rice-SDP) ត្រូវបានមើលឃើញថាជាក្របខ័ណ្ឌគោលដើម្បីបង្ហាញផ្លូវឆ្ពោះទៅរកការពង្រឹងការធ្វើពាណិជ្ជកម្មក្នុងវិស័យកសិកម្ម។ កម្មវិធីនេះក៏មានបំណងផ្តោតលើការធ្វើពាណិជ្ជកម្មស្រូវដែលផ្តោតលើភាពស៊ាំនៃប្រព័ន្ធគ្រប់គ្រងបរិស្ថានជាមូលដ្ឋានរបស់ដំណាំនេះ។ ការងារនេះអាចសម្រេចទៅបានតាមរយៈការកែសម្រួលលើក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ ព្រមជាមួយនឹងការពង្រឹងស្ថាប័ននៃតួអង្គដែលពាក់ព័ន្ធនានា។ កម្មវិធី Rice-SDP ត្រូវសម្រេចឱ្យបាននូវការពង្រឹងសមត្ថភាពនៃការផ្គត់ផ្គង់ស្បៀងតាមរយៈការបង្កើនផលិតភាពដំណាំស្រូវ និងការធ្វើពាណិជ្ជកម្ម ក៏ដូចជាការបន្ថែមគុណតម្លៃដល់ការផលិតស្រូវនៅក្នុងតំបន់របស់គម្រោង។ ដើម្បីសម្រេចបានតាមគោលដៅនេះ កម្មវិធី Rice-SDP ក៏មានគំនិតផ្តួចផ្តើមអភិវឌ្ឍយន្តការធានាគុណភាព

---

[1] ប្រភព៖ ឯកសារគម្រោង

គ្រាប់ពូជតាមរយៈប្រព័ន្ធបញ្ជាក់វិញ្ញាបនបត្រគ្រាប់ពូជ ក្នុងនោះសម្រាប់គ្រាប់ពូជគ្រឹះផលិតដោយ CARDI ឬម្ចាស់ពូជណាផ្សេងទៀត។ រីឯគ្រាប់ពូជចុះបញ្ជី និងគ្រាប់ពូជវិញ្ញាបនបត្រអាចផលិតដោយស្ថានីយកសិកម្ម ឬក្រុមកសិករផលិតគ្រាប់ពូជស្រូវបែបពាណិជ្ជកម្ម ឬសហគមន៍កសិកម្ម ឬក្រុមហ៊ុនឯកជនដែលមានឯកទេសកម្មផ្នែកផលិតកម្មគ្រាប់ពូជ។

## ២. វត្ថុបំណងរបស់សៀវភៅ

សៀវភៅណែនាំស្តីពី ផលិតកម្មគ្រាប់ពូជស្រូវ ផ្តោតលើការអភិវឌ្ឍយន្តការប្រមូលផ្តុំគ្រប់តួអង្គពាក់ព័ន្ធដែលចូលរួមនៅក្នុងខ្សែច្រវាក់ផលិតកម្មគ្រាប់ពូជស្រូវដើម្បីធ្វើយ៉ាងណាឱ្យបំពេញនូវភាពខ្វះចន្លោះនៃលក្ខខណ្ឌតម្រូវស្របតាមស្តង់ដារគ្រាប់ពូជសម្រាប់ផ្គត់ផ្គង់ដល់កសិករ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកទិញគ្រាប់ពូជស្រូវផ្សេងៗទៀតឱ្យបានគ្រប់គ្រាន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ឯកសារមួយចំនួនដែលត្រូវបានចងក្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឧបត្ថម្ភដោយគម្រោងផ្សេងៗទៀត[2] របស់ ADB អាចយកមកប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើបច្ចុប្បន្នភាពឯកសារដើម្បីពង្រឹងខ្សែច្រវាក់ផលិតកម្ម និងការផ្គត់ផ្គង់គ្រាប់ពូជស្រូវដែលមានគុណភាពដល់អ្នកប្រើប្រាស់។ តាមរយៈសៀវភៅណែនាំនេះ គ្រប់ភាគីពាក់ពន្ធ័ទាំងអស់ត្រូវអនុវត្តតាមនីតិវិធីស្តង់ដារ និងគោលការណ៍បច្ចេកទេសតែមួយដើម្បីលើកកម្ពស់គុណភាពគ្រាប់ពូជនាពេលបច្ចុប្បន្ន និងអនាគត។

វត្ថុបំណងសំខាន់នៃសៀវភៅណែនាំនេះគឺផ្តល់នូវក្របខ័ណ្ឌរួមមួយដើម្បីជួយភាគីពាក់ព័ន្ធដែលចូលរួមនៅក្នុងកម្មវិធីផលិតគ្រាប់ពូជស្រូវរបស់កម្មវិធី Rice-SDP ឱ្យអនុវត្តរាល់សកម្មភាពដែលបានគ្រោងទុកប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងបំពេញសកម្មភាពទាំងអស់នោះប្រកបដោយជោគជ័យ ផ្អែកលើបទពិសោធន៍ និងការអនុវត្តល្អៗដែលបានបង្ហាញនៅក្នុងឯកសារនេះ។

កម្មវិធី Rice-SDP ជឿជាក់ថា ផលិតកម្មគ្រាប់ពូជស្រូវមានគុណភាពតាមរយៈការធ្វើការជាមួយស្ថានីយកសិកម្ម សហគមន៍កសិកម្ម និងក្រុមកសិករផលិតគ្រាប់ពូជស្រូវ ព្រមទាំងការផ្តល់នូវការគាំទ្រផ្នែកបណ្តុះបណ្តាល និងត្រួតពិនិត្យគុណភាពដោយអគ្គនាយកដ្ឋានកសិកម្ម។ ការងារនេះមិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់អ្នកផលិតគ្រាប់ពូជប៉ុណ្ណោះទេ ប៉ុន្តែអាចផ្គត់ផ្គង់គ្រាប់ពូជស្រូវដែលមានគុណភាពដល់អ្នកប្រើប្រាស់ និងជួយបង្កើនសមត្ថភាពក្នុងការកសាងទំនាក់ទំនងទីផ្សារសម្រាប់ការធ្វើពាណិជ្ជកម្មគ្រាប់ពូជស្រូវមានគុណភាពទៅថ្ងៃអនាគត។ ទន្ទឹមនឹងនេះ កម្មវិធីក៏នឹងជួយពង្រឹងលទ្ធភាពផ្គង់ផ្គង់ និងស្វែងរកគ្រាប់ពូជស្រូវដែលមានគុណភាពដើម្បីធ្វើអាជីវកម្មសម្រាប់កសិករ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកទិញគ្រាប់

[2] ជាពិសេសក្រោមគម្រោងអភិវឌ្ឍន៍កសិករខ្នាតតូចតំបន់បឹងទន្លេសាប (TSSD) សៀវភៅណែនាំប្រតិបត្តិការដែលមានបញ្ចូលនូវកិច្ចព្រមព្រៀង (LoA) ផងនោះ ត្រូវបានចងក្រងឡើង និងត្រូវបានប្រើប្រាស់សម្រាប់ការទាក់ទងជាមួយនឹងស្ថានីយកសិកម្មដែលស្ថិតនៅក្នុងកម្មវិធីផលិតគ្រាប់ពូជស្រូវចុះបញ្ជី។ ចំណែកឯក្រោមគម្រោងជំនួយស្បៀងបន្ទាន់ (EFAP) ឯកសារកិច្ចសន្យាគម្រោងត្រូវបានបង្កើតឡើង និងប្រើប្រាស់សម្រាប់ការទាក់ទងជាមួយនឹងសហគមន៍កសិកម្ម/ក្រុមកសិករក្នុងកម្មវិធីផលិតគ្រាប់ពូជស្រូវវិញ្ញាបនបត្រ។ ឯកសារដែលត្រូវបានចងក្រងក្រោមគម្រោង EFAP នេះត្រូវបានប្រើប្រាស់ដោយរាជរដ្ឋាភិបាលកម្ពុជា (RGC) ដើម្បីផលិតកម្មគ្រាប់ពូជស្រូវមានគុណភាពសម្រាប់ធនធានគ្រាប់ពូជបម្រុងក្រោមប្រព័ន្ធធនធានស្បៀងបម្រុងកម្ពុជា (CFRS) របស់ខ្លួន។

ពូជស្រូវដទៃទៀត ព្រមទាំងលើកកម្ពស់គុណភាពស្រូវ និងអង្ករ ដើម្បីជំរុញការនាំចេញអង្ករទៅក្នុងទីផ្សារអន្តរជាតិ។ ជារួម កម្មវិធី Rice-SDP គឺធ្វើយ៉ាងណាសម្រេចឱ្យបាននូវកំណើនប្រកបដោយនិរន្តរភាពផលិតកម្មកសិកម្ម និងរក្សាបាននូវការផ្គត់ផ្គង់ស្បៀងគ្រប់គ្រាន់ តាមរយៈការបង្កើនលទ្ធភាពរបស់កសិករក្នុងការស្វែងរកគ្រាប់ពូជស្រូវមានគុណភាព ការពង្រឹងសមត្ថភាពរបស់ស្ថានីយកសិកម្ម សហគមន៍កសិកម្ម និងក្រុមកសិករផលិតពូជស្រូវក្នុងការផលិតគ្រាប់ពូជស្រូវដែលមានគុណភាពស្របតាមស្តង់ដារ។

## ៣. ការចាត់ថ្នាក់គ្រាប់ពូជស្រូវ

### ៣.១. ការចាត់ថ្នាក់គ្រាប់ពូជស្រូវ

កន្លងមកនៅប្រទេសកម្ពុជា ខណៈដែលឧស្សាហកម្មគ្រាប់ពូជស្ថិតក្នុងដំណាក់កាលអភិវឌ្ឍន៍នៅឡើយ ប្រភេទទី៦នៃចំណាត់ថ្នាក់គ្រាប់ពូជគឺគ្រាប់ពូជសុទ្ធល្អ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយជាលក្ខណៈពាណិជ្ជកម្មសម្រាប់ការដាំដុះជាស្រូវចំណី។ ប៉ុន្តែ ជាធម្មតា គ្រាប់ពូជស្រូវត្រូវបានចាត់ថ្នាក់ជា៥ប្រភេទខុសៗគ្នា អាស្រ័យលើជំនាន់របស់គ្រាប់ពូជ លក្ខខណ្ឌ និងការថែទាំក្នុងការផលិត ភាពសុទ្ធរបស់គ្រាប់ពូជ និងគោលបំណងនៃការផលិត។ ដូច្នេះ បច្ចុប្បន្ន ការចាត់ថ្នាក់គ្រាប់ពូជស្រូវនៅប្រទេសកម្ពុជាមានដូចខាងក្រោម ៖

- **គ្រាប់ពូជមេ (Nucleus seed)**៖ សំដៅដល់គ្រាប់ពូជស្រូវដែលត្រូវបានផលិត និងរក្សាទុកដោយរុក្ខជម្រើសវិទូ ហើយមិនមែនជាគ្រាប់ពូជស្រូវសម្រាប់ធ្វើពាណិជ្ជកម្មទេ។
- **គ្រាប់ពូជជម្រើសវិទូ (Breeder seed)**៖ សំដៅដល់គ្រាប់ពូជស្រូវដែលត្រូវបានផលិតដោយរុក្ខជម្រើសវិទូដោយប្រើប្រាស់គ្រាប់ពូជស្រូវមេ ដាំជាជួរ និងប្រើកួរស្រូវដែលបានប្រមូលពីពូជស្រូវមេ ហើយទទួលស្គាល់ពីស្ថាប័នដើមដែលជាអ្នកបង្កើតប្រភេទពូជស្រូវនេះមុនគេ។ គ្រាប់ពូជស្រូវជំរើសវិទូជាប្រភពសម្រាប់ផលិតគ្រាប់ពូជស្រូវនៃចំណាត់ថ្នាក់ដទៃទៀត ជាពិសេសសម្រាប់ផលិតកម្មគ្រាប់ពូជស្រូវគ្រឹះ។
- **គ្រាប់ពូជគ្រឹះ (Foundation seed)**៖ សំដៅដល់គ្រាប់ពូជស្រូវដែលត្រូវបានផលិតដោយរុក្ខជម្រើសវិទូដោយប្រើប្រាស់គ្រាប់ពូជជម្រើសវិទូ ស្ទូងជាជួរ១ដើមក្នុង១គុម្ព ឬដាំ១គ្រាប់ក្នុង១គុម្ព ក្រោមការត្រួតពិនិត្យផ្ទាល់ពីម្ចាស់ពូជ។ គ្រាប់ពូជគ្រឹះត្រូវបានផលិតក្រោមវិធានដែលបង្កើតដោយអង្គភាពបញ្ជាក់គុណភាពពូជដំណាំក្នុងគោលបំណងរក្សាភាពសុទ្ធពិន្ទុ និងអត្តសញ្ញាណរបស់ប្រភេទពូជស្រូវ។
- **គ្រាប់ពូជចុះបញ្ជី (Registered seed)**៖ សំដៅដល់គ្រាប់ពូជស្រូវដែលត្រូវបានផលិតដោយប្រើប្រាស់គ្រាប់ពូជគ្រឹះ ដោយត្រូវដាំជារជួរក្រោមវិធានដែលមានការទទួលស្គាល់ពីអង្គភាពបញ្ជាក់គុណភាពពូជដំណាំដើម្បីរក្សាភាពសុទ្ធពិន្ទុ និងអត្តសញ្ញាណរបស់ប្រភេទពូជ។
- **គ្រាប់ពូជវិញ្ញាបនបត្រ (Certified seed)**៖ សំដៅដល់គ្រាប់ពូជដំណាំដែលត្រូវបានផលិតដោយ ប្រើប្រាស់ពូជដំណាំចុះបញ្ជីក្រោមវិធានដែលមានការទទួលស្គាល់ពីអង្គភាពបញ្ជាក់គុណភាពពូជដំណាំដើម្បីរក្សាភាពសុទ្ធពិន្ទុ និងអត្តសញ្ញាណរបស់ប្រភេទពូជ។

## ៣.២. ស្តង់ដារគុណភាពគ្រាប់ពូជស្រូវ

ក្រោមក្របខ័ណ្ឌនៃកម្មវិធី Rice-SDP មានផែនការផលិតគ្រាប់ពូជគ្រឹះ គ្រាប់ពូជចុះបញ្ជី និងគ្រាប់ពូជវិញ្ញាបនបត្រតាមរយៈកិច្ចព្រមព្រៀងជាមួយនឹងអ្នកផលិតគ្រាប់ពូជស្រូវនានាដូចជា៖ CARDI កសិដ្ឋានឬស្ថានីយកសិកម្មដែលបានជ្រើសរើស សហគមន៍កសិកម្ម និងក្រុមកសិករផលិតគ្រាប់ពូជស្រូវនៅតាមខេត្តគោលដៅ។ ប៉ុន្តែសម្រាប់ការផលិតក្នុងទំហំច្រើននៃគ្រាប់ពូជស្រូវ កម្មវិធី Rice-SDP នឹងផ្តោតលើការផលិតគ្រាប់ពូជចុះបញ្ជី និងគ្រាប់ពូជវិញ្ញាបនបត្រប៉ុណ្ណោះសម្រាប់លក់ទៅឱ្យកសិករ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកទិញលក់គ្រាប់ពូជស្រូវផ្សេងទៀត។ ស្តង់ដារគុណភាពសម្រាប់ទីវាលស្រែផលិតពូជ និងប្រភេទគ្រាប់ពូជស្រូវនីមួយៗត្រូវបានបញ្ជាក់តាមឯកសារ **"ស្តង់ដារគ្រាប់ពូជស្រូវ និងនីតិវិធីវាយតម្លៃគុណភាព"** ដែលមានចែងដូចខាងក្រោម៖

### ស្តង់ដារស្រែអប្បបរមាសម្រាប់ផលិតកម្មគ្រាប់ពូជស្រូវ

| កត្តា | ចំនួនអតិបរមានៃរុក្ខជាតិលើដី ១០០ ម² | | |
|---|---|---|---|
| | គ្រាប់ពូជគ្រឹះ | គ្រាប់ពូជចុះបញ្ជី | គ្រាប់ពូជវិញ្ញាបនបត្រ |
| ១. ការលាយពូជស្រូវផ្សេង (គុម្ព) | ០ | ១ | ២ |
| ២. ស្មៅហាមឃាត់ (គុម្ព) | ០ | ៥ | ១០ |

- សម្គាល់: ស្មៅដែលហាមឃាត់រួមមាន៖
  - ស្មៅបែកក្បាល (Echinochloa sp.)
  - កក់ឆ័ត្រ (Cyperus iria)
  - ស្មៅកន្ទុយក្ងោក (Leptocloa Chinensis)